**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * * *

# ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទទួលឯកឧត្តម មៃ ឃើល៍ តាន់ កេង ស្យុង ឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា

នៅព្រឹកថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឲ្យ**ឯកឧត្តម មៃឃើល៍ តាន់ កេង ស្យុង** (Michael Tan Keng Siong) ឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា ក្នុងឱកាសដែលឯកឧត្តមបានបញ្ចប់បេសកកម្មការទូតនៅកម្ពុជា។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានអបអរសាទរចំពោះ**ឯកឧត្តមឯកអគ្គរដ្ឋទូត** ដែលបានបញ្ចប់បេសកកម្មការទូតប្រកបដោយជោគជ័យនៅកម្ពុជា ហើយនឹងទទួលមេដាយសហមេត្រីថ្នាក់មហាសេនាពីរាជរដ្ឋាភិបាលកម្ពុជា ចំពោះកិច្ចខិតខំប្រឹងប្រែង និងការរួមចំណែករបស់**ឯកឧត្តម**ក្នុងការពង្រឹងលើកកំពស់ចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរឲ្យកាន់តែរឹងមាំថែមទៀត។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានបញ្ជាក់ថា នៅក្នុងអាណត្តិរបស់ឯកឧត្តម **មៃ ឃើល៍ កេង ស្យុង** ប្រទេសទាំងពីរសម្រេចបាននូវសមិទ្ធផលជាច្រើនដូចជា ការផ្លាស់ប្តូរដំណើរទស្សនកិច្ចរវាងថ្នាក់ដឹកនាំកំពូលនៃប្រទេសទាំងពីរជាបន្តបន្ទាប់ ការកើនឡើងនៃទំហំពាណិជ្ជកម្មទ្វេភាគី ទំហំវិនិយោគរបស់សិង្ហបុរីនៅកម្ពុជា ព្រមទាំងបានរៀបចំឲ្យមានព្រឹត្តិការណ៍ Street Art Fest++ ដើម្បីអបអរសាទរខួបលើកទី៥៥នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសកម្ពុជានិងសិង្ហបុរី។

ជាការឆ្លើយតប **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានថ្លែងអំណរគុណដល់**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និងថ្នាក់ដឹកនាំ និងមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក៏ដូចជាក្រសួង/ស្ថាប័នពាក់ព័ន្ធ ក្នុងការរួមចំណែកធ្វើឱ្យបេសកកម្មរបស់**ឯកឧត្តម**នៅកម្ពុជា ទទួលបានជោគជ័យ។ នៅក្នុងឱកាសនោះ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានលើកឡើងអំពីសមិទ្ធផលចំនួន ០៣ ដែលឯកឧត្តមសម្រេចបានក្នុងអាណត្តិរបស់ឯកឧត្តម រួមមាន៖ (១) គម្រោងហេដ្ឋារចនាសម្ព័ន្ធអាស៊ី (Asia Infrastructure-AI) ដែលនឹងផ្តល់ផលប្រយោជន៍ដល់បណ្តាប្រទេសទន្លេមេគង្គ ដូចជា គម្រោងប្រែក្លាយកាកសំណល់ទៅជាថាមពល គម្រោងគ្រប់គ្រងកាកសំណល់ និងមជ្ឈមណ្ឌលឡូជីស្ទីកភ្នំពេញ (Phnom Penh Logistic Complex), (២)ការចូលរួមចំណែករបស់សហគមន៍សិង្ហបុរីនៅកម្ពុជាក្នុងការជួយដោះស្រាយការលំបាកនានារបស់ប្រជាជនកម្ពុជា រួមមានការផ្តល់មូលនិធិជូនដល់ជនរងគ្រោះដោយសារគ្រោះមហន្តរាយជំនន់

ទឹកភ្លៀងកាលពីខែតុលាថ្មីៗនេះ និងការចូលរួមជាវិភាគទានជាថវិកាដែលប្រមូលបានតាមរយៈព្រឹត្តិការណ៍ Street Art Fest++ ជូនដល់មូលនិធិកុមារកម្ពុជា និងសិល្បៈកម្ពុជាអមតៈ និង (៣) ការពង្រឹងទំនាក់ទំនង និងចំណងមិត្តភាពរវាងប្រជាជន និងប្រជាជន នៃប្រទេសទាំងពីរ ឲ្យកាន់តែរឹងមាំ។

ឆ្លៀតក្នុងឱកាសនោះដែរ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណស្ថានទូត និងសហគមន៍សិង្ហបុរីនៅកម្ពុជា ដែលបានជួយជនរងគ្រោះដោយសារគ្រោះទឹកជំនន់នាពេលកន្លងមក។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានវាយតម្លៃខ្ពស់ចំពោះការរួមចំណែករបស់ប្រទេសសិង្ហបុរី ក្នុងការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា ជាពិសេសក្រោមក្របខណ្ឌគំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ាន និងមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-សិង្ហបុរី ដែលបានជួយបណ្តុះបណ្តាលមន្ត្រីកម្ពុជា ទាំងនៅប្រទេសកម្ពុជា និងប្រទេសសិង្ហបុរី ព្រមទាំងការផ្តល់អាហារូបករណ៍ដល់សិស្ស-និស្សិតកម្ពុជាឱ្យបានបន្តការសិក្សាជាបន្តបន្ទាប់នៅប្រទេសសិង្ហបុរី។

ចំពោះទំនាក់ទំនងរវាងក្រសួងការបរទេសនៃប្រទេសទាំងពីរ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីសារសំខាន់នៃការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចពិគ្រោះយោបល់នយោបាយ រវាងក្រសួងការបរទេសទាំងពីរ និងការពង្រឹងកិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថាននយោបាយសាធារណៈលី ក្វាន់យូ ជាមួយនឹងវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិកម្ពុជា។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានបន្ថែមថា កម្ពុជា និងសិង្ហបុរី នឹងបន្តធ្វើការយ៉ាងជិតស្និទ្ធដើម្បីជំរុញកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគីបន្ថែមទៀតដើម្បីផលប្រយោជន៍សម្រាប់ប្រទេសទាំងពីរ តំបន់ និងពិភពលោក។

នៅចុងបញ្ចប់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជូនពរឯកឧត្តមឯកអគ្គរដ្ឋទូត **ម៉ៃឃើល តាន់ កេង ស្យុង** បន្តទទួលបានជោគជ័យថែមទៀតនៅក្នុងភារកិច្ចថ្មីរបស់ឯកឧត្តម៕